# សោណនន្ទជាតក

(គុណមាតាបិតា)



ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

រៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ
គុល ផេង

ព.ស. ២៥៦៣

# សោណនន្ទជាតក

# (គុណមាតាបិតា)





## ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា

## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា


*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**គុល ផេង**



**ព.ស. ២៥៦៣**

# សោណានន្ទជាតក

## បច្ចុប្បន្ននិទាន

ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតាមួយរូប បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទេវតា នុសិ គន្ធព្វោ** ដូច្នេះជាដើម។

រឿងភិក្ខុចិញ្ចឹមម្តាយនេះ មានដំណើររឿងដូចដែលបានសម្តែងក្នុង**សាមជាតក** (បិដកលេខ៦២ទំព័រ ៤៩) រួចហើយ។ មានសេចក្តីតំណាលថា ពេលនោះព្រះសាស្តាទ្រង់ប្រៀនប្រដៅភិក្ខុសង្ឃថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំតិះដៀលភិក្ខុនេះឡើយ បោរាណបណ្ឌិតទាំងឡាយ សូម្បីបានរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ក៏មិនកាន់យកនូវរាជសម្បត្តិនោះ

ឡើយ សុខចិត្តនៅចិញ្ចឹមបម្រើមាតាបិតា ទើបទ្រង់នាំអតីតនិទានមកសម្ដែងថា ៖

## អតីតនិទាន

ក្នុងអតីតកាល ទីក្រុងពារាណសីមានឈ្មោះថា **ព្រហ្មវឌ្ឍនៈ**។ ព្រះរាជាព្រះនាម **មនោជៈ** សោយរាជសម្បត្តិក្នុងនគរនោះ។ ក្នុងព្រហ្មវឌ្ឍនៈនោះ មានត្រកូលព្រាហ្មណមហាសាលមួយ មានទ្រព្យ ៨០ កោដិ ជាត្រកូលមិនមានបុត្រស្នងសោះ។ នាងព្រាហ្មណីនៃត្រកូលនោះត្រូវព្រាហ្មណ៍ជាស្វាមីបង្គាប់ថា នែនាង  នាងចូរប្រាថ្នាបុត្រ។ នាងព្រាហ្មណីក៏ប្រាថ្នាយ៉ាងនោះ។ ពេលនោះ ព្រះពោធិសត្វបានច្យុតចាកព្រហ្មលោកមកកាន់យកបដិសន្ធិក្នុងផ្ទៃនៃនាងព្រាហ្មណីនោះ។ កាលព្រះពោធិសត្វប្រសូតហើយ

មាតាបិតាក៏បានដាក់ឈ្មោះថា **សោណកុមារ**។ កាលដែលសោណកុមារនោះចេះដើរហើយ មានសត្វដទៃទៀតបានច្យុតចាកព្រហ្មលោក មកចាប់កំណើតក្នុងផ្ទៃនៃនាងព្រាហ្មណីនោះមួយនាក់ទៀត មាតាបិតាក៏បានដាក់ឈ្មោះទារកដែលកើតហើយនោះថា **នន្ទកុមារ** ។ ព្រាហ្មណ៍ជាបិតាកាលពិនិត្យឃើញនូវរូបសម្បត្តិរបស់បុត្រទាំងពីរ ដែលពេញវ័យហើយ មានត្រៃវេទរៀនចប់ហើយ ដល់នូវភាពជំនាញក្នុងសិល្បសាស្ត្រចិញ្ចឹមជីវិតគ្រប់យ៉ាងហើយ ក៏ប្រឹក្សាជាមួយនាងព្រាហ្មណីជាភរិយាថា នែនាងដ៏ចម្រើន យើងនឹងចងកូនសោណកុមារដោយចំណងផ្ទះឲ្យបាន។ នាងព្រាហ្មណីជាភរិយាទទួលថា សាធុ ល្អ ហើយក៏ប្រាប់សេចក្តីនោះដល់កូន។ សោណកុមារតបទៅម្តាយថា បពិត្រអ្នកម៉ែ ការរស់នៅជាឃរាវាសរបស់ខ្ញុំប៉ុណ្ណឹង

គ្រប់គ្រាន់ហើយ កូននឹងបម្រើលោកទាំងពីរដរាបដល់អស់ជីវិត អំណឹះអំពីលោកទាំងពីរទៅ កូននឹងចូលទៅក្នុងព្រៃហេមពាន្តហើយបួស។ នាងព្រាហ្មណីនោះក៏ជម្រាបសេចក្តីនុ៎ះដល់ព្រាហ្មណ៍ជាស្វាមី។

## អ្នកជាំង៤ចេញសាងផ្នួស

សូម្បីមាតាបិតាឃាត់អង្វរ ជាច្រើនដងយ៉ាងណាក៏ដោយ ក៏មិនអាចបង្វែរចិត្តរបស់សោណកុមារបានឡើយ ទើបនិយាយនឹងនន្ទកុមារថា នែបា បើដូច្នោះ ចូរបាគ្រប់គ្រងទ្រព្យសម្បត្តិចុះ។ នន្ទកុមារក៏ប្រកែកថា ខ្ញុំមិនឱនក្បាលលិឍទឹកមាត់ដែលបងប្រុសខ្ជាក់ចោលជាដាច់ខាត តែអំណឹះផុតអំពីលោកទាំងពីរទៅ ខ្ញុំនឹងទៅបួសជាមួយបងប្រុសដែរ។ មាតាបិតាកាលស្តាប់សម្តីកូនប្រុសទាំងពីរយ៉ាងនេះហើយ

ក៏គិតថា កូនទាំងពីរនេះនៅក្មេងកំលោះស្រស់ត្រកាល
យ៉ាងនេះក៏គង់លះបង់នូវកាមទាំងឡាយបាន ចុះនឹង
បាច់ពោលទៅថ្វីដល់យើង ពួកយើងនឹងបួសទាំងអស់
គ្នាតែម្តងទៅៗ លុះគិតដូច្នោះហើយ ក៏ហៅកូនមក
ប្រាប់ថា ហៃបាទាំងពីរ ពួកបាមិនចាំបាច់អស់ពីពួក
យើងទៅ សឹមបួសនោះទេ ពួកយើងនឹងបួសទាំងអស់
គ្នាឥឡូវនេះតែម្តង មិនល្អទេឬ រួចក៏ក្រាបទូលដំណឹង
ដល់ព្រះរាជា ហើយលះទ្រព្យសម្បត្តិទាំងអស់ឲ្យទៅ
ជាទាន ដោះលែងអ្នកបម្រើឲ្យទៅជាអ្នកជាវិញ (និង)
ឲ្យទ្រព្យដែលគួរឲ្យដល់ពពួកញាតិទាំងឡាយ
ស្រេចបាច់ហើយ ពួកគេទាំងបួននាក់ ដើរចេញពី
ព្រហ្មវឌ្ឍននគរ ទៅអាស្រ័យនូវស្រះដ៏ដេរដាស
ដោយឈូកមានពណ៌ប្រាំ នាហិមវន្តប្រទេស ក្នុង
ដងព្រៃដ៏គួរជាទីរីករាយ បានសាងអាស្រមហើយបួស

ហើយរស់នៅទីនោះៗ បងប្អូនប្រុសទាំងពីរនាក់ទំនុកបម្រុងមាតាបិតាដោយប្រការយ៉ាងនេះគឺ ៖

ពេលព្រឹករៀបចំជូនឈើជម្រះធ្មេញ និងទឹកសម្រាប់លុបមុខដល់លោកទាំងពីរ, បោសសម្អាតបណ្ណសាលា និងបរិវេណជុំវិញ, ទៅដងទឹកសម្រាប់ប្រើប្រាស់ និងទឹកសម្រាប់ផឹកមកតម្កល់ទុកជាស្រេច រួចទើបយកផ្លែឈើទុំខ្ចីដ៏មានឱជារសផ្អែមឈ្ងុយឆ្ងាញ់មកអំពីព្រៃជូនមាតាបិតាពិសា ផ្ងូតលោកទាំងពីរដោយទឹកក្តៅទឹកត្រជាក់ សម្អាតផ្ទះសក់ និងធ្វើកាតព្វកិច្ចដែលគួរធ្វើដល់លោកទាំងពីរ មានលាងជើងជាដើមៗ ការទំនុកបម្រុងដោយប្រការយ៉ាងនេះកន្លងទៅអស់កាលដ៏យូរ ថ្ងៃមួយ នៅតាមផ្លូវកំពុងស្វែងរកផ្លែឈើ នន្ទបណ្ឌិតក៏គិតថា អាត្មាអញនឹងជូន

មាតាបិតាឲ្យលោកពិសាផលាផលដែលអញបានបេះមកហើយឲ្យបានមុន ដូច្នេះក៏ស្រួតទៅមុនបង ហើយយកផ្លែឈើផ្សេងៗ ដែលខ្លួនបានបេះយកមកតាំងពីថ្ងៃម្សិលមិញ ឬម្សិលម្ង៉ៃ នាំមកពីព្រឹកបង្អោនជូនមាតាបិតាពិសា។ លោកទាំងពីរបរិភោគផ្លែឈើទាំងនោះហើយក៏ខ្ចរមាត់រក្សាឧបោសថ។

ចំណែកសោណបណ្ឌិតទៅកាន់ទីឆ្ងាយ បេះយកផ្លែឈើទុំក្រហមឆ្អៅល្អៗ មានរសផ្អែមឈ្ងុយឆ្ងាញ់ដូចទឹកឃ្មុំ បង្អោនចូលមកជូនលោកពិសា។ ពេលនោះ មាតាបិតាពោលទៅកាន់គាត់ថា នែបា ពួកយើងបរិភោគផលាផលដែលប្អូនឯងយកមកតាំងពីព្រឹករួចហើយ ពួកយើងជាអ្នករក្សាឧបោសថ ពេលនេះមិនត្រូវការរបស់បាទៀតទេ។ ផលាផលទាំងឡាយរបស់

សោណបណ្ឌិតនោះ ដោយមិនត្រូវបានគេបរិភោគ ក៏ស្អុយរលួយអស់ទៅដោយប្រការយ៉ាងនេះ សូម្បីថ្ងៃស្អែក នន្ទបណ្ឌិតក៏នៅតែធ្វើយ៉ាងនោះដដែល។ សោណបណ្ឌិតជាបង ក៏នៅតែនិមន្តទៅទីឆ្ងាយដូចដើម ព្រោះលោកបានសម្រេចអភិញ្ញា៥ ហើយបេះផ្លែឈើយកមក តែពួកលោកទាំងពីរមិនបរិភោគ។

## សោណបណ្ឌិតបណ្តេញនន្ទបណ្ឌិត

គ្រានោះ ព្រះមហាសត្វគិតថា មាតាបិតារបស់អាត្មាអញជាសុខុមាលជាតិ ប្អូននន្ទតែងតែនាំយកផលាផលផ្សេងៗពីនេះពីនោះ ដែលមិនទាន់ទុំល្អមកជូនលោកពិសា កាលបើយ៉ាងនេះ ពួកគាត់នឹងមិនមានសុខភាពមាំទាំបានយូរអង្វែងឡើយ អញត្រូវតែឃាត់ប្អូននន្ទ។ ពេលនោះ តាបសបងក៏ហៅតាបសប្អូន

មកប្រាប់ថា នៃនន្ទ ចាប់ពីថ្ងៃនេះទៅ កាលដែលប្អូន
បេះផ្លៃឈើទុំខ្ចីបានមកហើយ ចូរចាំបងមកដល់សិន
សឹមយើងទាំងពីរនាក់បង្អោនជូនមាតាបិតាឲ្យគាត់
ពិសាជាមួយគ្នាតែម្តង។ នន្ទជាប្អូននោះ សូម្បីសោណ-
បណ្ឌិតប្រាប់យ៉ាងនេះហើយក៏ដោយ នៅគិតចង់បាន
បុណ្យតែម្នាក់ឯង មិនបានធ្វើតាមពាក្យបងឡើយ។
ព្រះមហាសត្វគិតថា នន្ទមិនស្តាប់បង្គាប់យើងទេ
ហើយធ្វើកម្មមិនសមគួរសោះ យើងនឹងបណ្តេញគេ
ចេញ ហើយចាប់ពីពេលនេះទៅ យើងនឹងបម្រើមាតា
បិតាតែម្នាក់ឯងចុះ លុះគិតហើយ ក៏ហៅតាបសប្អូន
មកបណ្តេញចេញដោយពាក្យថា នៃនន្ទ ឯងជា
មនុស្សមិនស្តាប់ឱវាទ មិនធ្វើតាមពាក្យបណ្ឌិត យើង
ជាបងអ្នក ភារៈចិញ្ចឹមមាតាបិតាជារបស់យើងពិត
យើងនឹងទំនុកបម្រុងពួកលោកតែម្នាក់ឯង ឯងមិនត្រូវ

នៅទីនេះទៀតទេ ចូរទៅនៅក្នុងទីដទៃចុះ ថាហើយ ក៏វាយម្រាមដៃនន្ទបណ្ឌិតនោះ។

## ឧទ្ធបណ្ឌិតរកាវិធីសូមទោសសោណបណ្ឌិត

នន្ទបណ្ឌិតជាប្អូន ត្រូវតាបសបងបណ្ដេញហើយ ក៏មិនអាចនឹងឈរនៅក្នុងសំណាក់សោណ-បណ្ឌិតនោះបានទៀតឡើយ ហើយក៏ថ្វាយបង្គំលាបងចូលទៅរកមាតាបិតារៀបរាប់ប្រាប់សេចក្ដីនោះសព្វគ្រប់ បន្ទាប់មកក៏ចូលទៅក្នុងបណ្ណសាលារបស់ខ្លួនសម្លឹងកសិណនិមិត្ត ញ៉ាំងអភិញ្ញា៥ និងសមាបត្តិ៨ឲ្យកើតឡើងក្នុងថ្ងៃនោះឯង រួចគិតថា បើអាត្មាអញទៅកើបយកខ្សាច់រតនៈទាំងឡាយពីជើងភ្នំសិនេរុ មកចាក់រោយត្រង់បរិវេណបណ្ណសាលា របស់បងប្រុសអញ តើសមល្មមដើម្បីនឹងឲ្យបងប្រុសអត់ទោសឲ្យ

បានដែរទេ សូម្បីធ្វើយ៉ាងនេះ ក៏នៅតែមិនសមរម្យ ឡើយ, តែបើអាត្មាអញទៅជងយកទឹកអំពីអនោតត្ត- ស្រះ មកចាក់ស្រោចស្រពត្រង់បរិវេណបណ្ណសាលា របស់បងប្រុសអញ តើសមល្មមដើម្បីនឹងឲ្យបងប្រុស អត់ទោសឲ្យបានដែរទេ សូម្បីធ្វើយ៉ាងនេះ ក៏នៅតែ មិនសមរម្យដែរ, ប្រសិនបើបងប្រុសអាចអត់ទោសឲ្យ យើងបាន ដោយអំណាចនៃពួកទេវតាទាំងឡាយ តើ យើងនាំស្តេចមហារាជទាំង៤និងសក្កទេវរាជមក ល្មម នឹងឲ្យបងប្រុសអត់ទោសឲ្យបានដែរឬទេ សូម្បីធ្វើ យ៉ាងនេះ ក៏នៅតែមិនសមរម្យដែរ, បើអញ្ចឹងមានតែ យើងនឹងនាំព្រះរាជាទាំងឡាយ មានព្រះបាទមនោជៈ ជាអគ្គរាជាជាប្រធានមកសូមខមាទោសចុះ កាលបើ ធ្វើយ៉ាងនេះ កិត្តិគុណរបស់បងប្រុសរបស់យើងនឹង ផ្សាយ គ្របដណ្តប់ទៅទូទាំងសកលជម្ពូទ្វីប នឹង

ចិញ្ចែងចិញ្ចាចដូចជាព្រះចន្ទ និងព្រះអាទិត្យ។ នន្ទ-បណ្ឌិតនោះហោះដោយឫទ្ធិ ទៅចុះនៅត្រង់មាត់ទ្វារព្រះរាជវាំងនៃព្រះរាជានោះនៅឯព្រហ្មវឌ្ឍននគរ ឲ្យគេទៅក្រាបទូលព្រះរាជាថា បានឮថា មានតាបសមួយរូបចង់ចូលគាល់ព្រះអង្គ។ ព្រះរាជាទ្រង់ព្រះតម្រិះថាប្រយោជន៍អ្វី ដោយការដែលយើងជួបបព្វជិត លោកមកដើម្បីតែអាហារប៉ុណ្ណោះ ក៏បញ្ជូនចង្ហាន់ទៅប្រគេន។ តែតាបសមិនប្រាថ្នាចង្ហាន់ឡើយ។ ទ្រង់ក៏បញ្ជូនអង្ករទៅប្រគេន។ លោកមិនត្រូវការអង្ករទៀត។ ទ្រង់បញ្ជូនសំពត់ទាំងឡាយទៅប្រគេន។ លោកក៏មិនត្រូវការសំពត់ទាំងនោះដែរ។ ទ្រង់ក៏បញ្ជូនម្លូទៅប្រគេន។ លោកក៏មិនទទួលម្លូដែរ។ គ្រានោះព្រះរាជាទ្រង់បញ្ជូនទូតទៅកាន់សំណាក់នន្ទតាបសនោះថា តើព្រះតេជគុណនិមន្តមកដើម្បីអ្វី? នន្ទ-

បណ្ឌិតតាបសដែលទូតសួរហើយ ក៏ពោលថាអាត្មា
មកដើម្បីគាល់បម្រើព្រះរាជា។ ព្រះរាជាទ្រង់ព្រះ
សណ្ដាប់ពាក្យនោះហើយក៏បញ្ជូនទូតទៅថា អ្នក
គាល់បម្រើរបស់យើងមានច្រើនហើយ ចូរព្រះតេជ-
គុណនិមន្តចម្រើនតបធម៌របស់ខ្លួនចុះ។ តាបសឮ
ពាក្យនោះហើយក៏ពោលថា អាត្មានឹងដណ្ដើមយក
រាជសម្បត្តិក្នុងជម្ពូទ្វីបទាំងអស់ដោយកម្លាំងរបស់
អាត្មា មកថ្វាយព្រះអង្គ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់
ដំណឹងនោះហើយទ្រង់ព្រះតម្រិះថា ធម្មតាបព្វជិត
ទាំងឡាយ គឺជាបណ្ឌិតតែងដឹងឧបាយជាមិនខាន
លុះទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ក៏ឲ្យគេទៅនិមន្ត
នន្ទតាបស មកឲ្យគង់លើអាសនៈ ថ្វាយបង្គំតាបសរួច
ទ្រង់មានព្រះបន្ទូលសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន
ឮថា លោកម្ចាស់អាចដណ្ដើមយករាជសម្បត្តិទូទាំង

សកលជម្ពូទ្វីបមកប្រគល់ដល់ខ្ញុំព្រះករុណាឬ? នន្ទ-តាបសថ្វាយព្រះពរថា បពិត្រមហារាជ ពិតមែនហើយ។

**ព្រះរាជា៖** តើលោកម្ចាស់នឹងដណ្ដើមយកយ៉ាងម៉េច?

**តាបស៖** បពិត្រមហារាជ អាត្មាភាពមិនបង្ហូរឈាមជនណាម្នាក់ឡើយ ដោយហោចទៅសូម្បីតែត្រឹមមួយចម្អែតរុយ ទាំងមិនចំណាយព្រះរាជទ្រព្យរបស់ព្រះអង្គទេ អាត្មានឹងដណ្ដើមយកមកថ្វាយព្រះអង្គដោយឫទ្ធិរបស់អាត្មាតែម្យ៉ាង តែថាព្រះអង្គមិនគួរធ្វើឲ្យយឺតយូរអស់ពេលមានប៉ុណ្ណោះឡើយ គួរតែចេញដំណើរក្នុងថ្ងៃនេះឯង។

ព្រះបាទមនោជៈជឿសម្ដីរបស់នន្ទតាបស ទ្រង់រៀបចំហែហមដោយពលសេនារក្សាអង្គចេញចាកព្រះនគរទៅ។ បើមានកម្ដៅថ្ងៃ ក្ដៅទៅលើកងទ័ព

នន្ទបណ្ឌិតក៏និម្មិតស្រមោលម្ហូបដោយឫទ្ធិរបស់ខ្លួន ធ្វើឲ្យត្រជាក់វិញ ទុកណាបើកាលមានភ្លៀងបង្អុរចុះ លោកមិនឲ្យភ្លៀងទទឹកកងទ័ពឡើយ លោកតែង ការពារបញ្ចៀសត្រជាក់ផង កម្ដៅផង ញុំាងអន្តរាយទាំងឡាយទាំងពួងមានទាំងដង្គត់ឈើនិងបន្លាជាដើម ឲ្យវិនាសបាត់អស់ លោកធ្វើផ្លូវឲ្យស្មើប្រៀបដូចជាកសិណមណ្ឌល ក្រាលនូវប្រឫមខណ្ឌព្ធដ៏អាកាស ខ្លួនលោកអង្គុយពែនភ្នែន ហែហមដោយពលសេនានិមន្តទៅៗ

## ការដណ្តើមយកប្រទេសចាំង ១០១

នន្ទបណ្ឌិតតាបស ដឹកនាំកងទ័ពមានប្រការយ៉ាងនេះ ក៏បានទៅដល់ដែនកោសលជាដំបូង ឲ្យកងទ័ពបោះបន្ទាយស្នាក់នៅជិតព្រះនគរ រួចបញ្ជូនទូត

ទៅថ្វាយស្ដេចកោសលថា ព្រះរាជាត្រូវប្រយុទ្ធ ឬ
ប្រគល់ស្វេតឆ្ឆត្រ។ ព្រះបាទកោសលទ្រង់ព្រះពិរោធ
ជាខ្លាំង ដោយព្រះតម្រិះថា ពួកនេះមិនទុកយើងជា
ស្ដេចទេឬ ក៏តបព្រះរាជឱង្ការទៅថា យើងនឹងប្រយុទ្ធ
តតាំងគ្នា ហើយក៏នាំមុខពលសេនាចេញទៅ។ កងទ័ព
ទាំងពីរប្រោះព្រួនឹងច្បាំងគ្នា។ នន្ទបណ្ឌិតក៏និម្មិតនិសីទនៈ
ស្បែកខ្លារខិនយ៉ាងធំ ពាំងត្រង់ចន្លោះកងទ័ពទាំងពីរ
លាតសន្ធឹងចាំទទួលនូវផ្លែព្រួញ ដែលកងទ័ពទាំង
សងខាងបាញ់ចេញទៅ ដោយកម្រាលស្បែកនោះ។
មិនមានសូម្បីទាហានម្នាក់នៃកងទ័ពម្ខាងណា ត្រូវ
បាញ់មុតដោយព្រួញឡើយ ។ កងទ័ពទាំងសងខាងក៏
ឈប់បាញ់តទៅទៀតដែរ ព្រោះអស់កូនសរពីដៃ។
នន្ទបណ្ឌិតក៏ចូលទៅកាន់សំណាក់ព្រះបាទមនោជៈ
លួងលោមព្រះអង្គថា បពិត្រមហារាជ សូមទ្រង់កុំភ័យ

ឡើយ ហើយនិមន្តទៅកាន់សំណាក់ព្រះបាទកោសល
ហើយថ្វាយព្រះពរទូលទៅថា បពិត្រមហារាជ សូម
ទ្រង់កុំភ័យឡើយ សេចក្ដីអន្តរាយនឹងមិនមានដល់ព្រះ
អង្គឡើយ រាជ្យរបស់ព្រះអង្គនឹងនៅតែជារបស់ទ្រង់
ដដែល តែសូមទ្រង់ស្ថិតនៅក្រោមអំណាចរបស់
ព្រះបាទមនោជៈ។ ព្រះអង្គស្ដាប់តាមពាក្យតាបស
ហើយ ក៏ទទួលថា សាធុប្រពៃហើយ។ នន្ទបណ្ឌិតក៏នាំ
ព្រះបាទកោសល ទៅកាន់សំណាក់ព្រះបាទមនោជៈ
ហើយទូលព្រះឱង្ការថា បពិត្រមហារាជ ព្រះបាទ
កោសលព្រមចំណុះក្នុងអាជ្ញារបស់ទ្រង់ហើយ រាជ-
សម្បត្តិរបស់ស្ដេចអង្គនេះចូរនៅជារបស់ស្ដេចអង្គ
នោះដដែលចុះ ក្រាបទូល។ ព្រះបាទមនោជៈទទួល
ព្រមថា សាធុ ប្រពៃហើយ ក៏ឲ្យព្រះបាទកោសលអង្គ
នោះប្រព្រឹត្តតាមអាជ្ញារបស់ទ្រង់ ហើយនាំយកកងទ័ព

ទាំងពីរនគរទៅកាន់ដែនអង្គៈដណ្ដើមយកដែនអង្គៈ ហើយក៏ចេញពីទីនោះទៅយកដែនមគធៈទៀត ទ្រង់ដណ្ដើមបានដែនមគធៈដោយឧបាយនេះឯង។ ព្រះបាទមនោជៈញ៉ាំងព្រះរាជាទាំងឡាយក្នុងជម្ពូទ្វីបទាំងមូល ឲ្យចំណុះក្នុងអំណាចរបស់ព្រះអង្គ។ បន្ទាប់មក ទ្រង់ហែហមចោមជុំដោយកងទ័ព និងព្រះរាជាមានប្រមាណប៉ុណ្ណោះ យាងត្រឡប់សំដៅទៅព្រហ្មវឌ្ឍននគរវិញ ដោយប្រការយ៉ាងនេះឯង។ ព្រះអង្គបានចំណាយពេលប្រាំពីរឆ្នាំប្រាំពីរខែ ប្រាំពីរថ្ងៃ ច្បាំងដណ្ដើមយករាជសម្បត្តិទាំងនោះ។ ព្រះបាទមនោជៈទ្រង់ត្រាស់បញ្ជាឲ្យព្រះរាជាទាំងនោះ នាំយកនូវបង្អែម និងចង្អាបមានប្រការប្លែក ៗ ផ្សេងៗ មកអំពីរាជធានីនីមួយៗ ទ្រង់នាំព្រះរាជាទាំង ១០១ ព្រះអង្គ

សោយទឹកបានៈយ៉ាងច្រើនប្រភេទ ជាមួយព្រះរាជា ទាំងនោះ អស់ ៧ ថ្ងៃ ។

## ឆន្ទតាបសមិនត្រូវការរាជ្យក្នុងជម្ពូទ្វីប

នន្ទបណ្ឌិតគិតថា យើងនឹងមិនបង្ហាញខ្លួនអស់ ៧ ថ្ងៃ ហើយនឹងទៅបិណ្ឌបាតនៅឧត្តរកុរុទ្វីប អាស្រ័យនៅទៀបទ្វារកញ្ចនគុហា ឯហិមវន្តប្រទេស អស់ ៧ ថ្ងៃដែរ។ ក្នុងថ្ងៃទី ៧ ព្រះបាទមនោជៈ កាលទ្រង់សម្លឹងពិចារណាមើលសិរីសម្បត្តិដ៏មហិមារបស់ទ្រង់ ទើបរឭកដល់នន្ទបណ្ឌិតថា យសសម្បត្តិនេះ មិនមែនជារបស់ដែលព្រះមាតាព្រះបិតាឲ្យដល់យើងទេ ទាំងមិនមែនបុគ្គលទាំងឡាយដទៃណាឲ្យដល់យើងដែរ យសសម្បត្តិនុ៎ះ កើតឡើង ព្រោះអាស្រ័យនន្ទតាបសមែនពិត តែថ្ងៃនេះជាថ្ងៃទី ៧ ហើយ ដែល

យើងមិនបានឃើញលោក ឱហ្ន៎ តើអ្នកឲ្យយសសម្បត្តិដល់យើងនិមន្តទៅទីណាហើយ។ នន្ទបណ្ឌិតនោះដឹងភាពដែលព្រះបាទមនោជៈនឹករឭកដល់ខ្លួន ក៏និមន្តមក តាំងនៅឰដ៏អាកាសខាងមុខព្រះរាជា។ ព្រះរាជាទ្រង់ទតឃើញហើយ ក៏ព្រះតម្រិះថា យើងមិនទាន់ដឹងនូវភាវៈនៃតាបសនេះជាទេវតា ឬជាមនុស្សនៅឡើយទេ ប្រសិនបើលោកជាមនុស្ស យើងនឹងប្រគល់រាជសម្បត្តិទូទាំងសកលជម្ពូទ្វីបដល់លោកភ្លាម។ តែបើជាទេវតា យើងនឹងធ្វើសក្ការបូជាដល់លោក។ ព្រះអង្គកាលចង់ដឹងភាវៈរបស់តាបស ក៏ត្រាស់គាថាទីមួយថា ៖

**ទេវតា នុសិ គន្ធព្វោ, អទុ សក្កោ បុរិន្ទទោ;**
**មនុស្សភូតោ ឥទ្ធិមា, កថំ ជានេមុ តំ មយំ ។**

លោកជាទេវតាឬជាគន្ធព្វ ជាសក្កបុរិន្ទទៈ ឬជាមនុស្សមានឫទ្ធិ ធ្វើដូចម្ដេច យើងនឹងស្គាល់លោកបាន។

នន្ទបណ្ឌិតស្ដាប់ពាក្យនោះហើយ កាលប្រាប់សេចក្ដីពិត ក៏ពោលគាថាទីពីរថា ៖

នាបិ ទេវោ ន គន្ធព្វោ,នាបិ សក្កោ បុរិន្ទទោ;
មនុស្សក្យោ ឥទ្ធិមា, ឯវំ ជានាហិ ភារត ។

អាត្មាភាពមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ អាត្មាភាពជាមនុស្សមានឫទ្ធិ បពិត្រព្រះរាជាទ្រទ្រង់នូវភារៈ (ដែន) សូមព្រះអង្គជ្រាបយ៉ាងនេះចុះ។

ព្រះរាជាព្រះសណ្ដាប់ហើយ ទ្រង់ព្រះតម្រិះថា បានឮថា មនុស្សភូតនេះ មានឧបការៈដ៏ធំធេងយ៉ាង

នេះចំពោះយើង យើងនឹងញុំាងមនុស្សនេះឲ្យរីករាយ ស្កប់ស្កល់ដោយយសដ៏ខ្ពង់ខ្ពស់ ទើបត្រាស់ថា៖

**កាតរូបមិទំ ភោតោ, វេយ្យាវច្ចំ អនប្បកំ;**
**ទេវម្ហិ វស្សមានម្ហិ, អនោវស្សំ ភវំ អគា ។**

ការខ្វល់ខ្វាយបម្រើ មានភាពដែលលោកដ៏ចម្រើនធ្វើហើយ នេះជាការមិនមែនតិច កាលដែលភ្លៀងកំពុងធ្លាក់ចុះ លោកដ៏ចម្រើនអាចធ្វើមិនឲ្យមានភ្លៀងបាន។

**តតោ វាតាតបេ ឃោរេ, សីតច្ឆាយំ ភវំ អគា;**
**តតោ អមិត្តមជ្ឈេសុ, សរតាណំ ភវំ អគា ។**

តអំពីនោះមក លោកដ៏ចម្រើនអាចធ្វើឲ្យម្លប់ដ៏ត្រជាក់បាន ក្នុងទីមានខ្យល់ និងកម្ដៅថ្ងៃដ៏ខ្លាំង តពី

នោះមក លោកដ៏ចម្រើនអាចធ្វើគ្រឿងការពារព្រួញ
ក្នុងកណ្ដាលនៃសត្រូវទាំងឡាយបាន។

តតោ ជីតានិ រដ្ឋានិ, វសិនោ តេ ករំ អកា;
តតោ ឯកសតំ ខត្យេ, អនុយន្តេ ករំ អកា ។

តពីនោះមក លោកដ៏ចម្រើនអាចធ្វើដែនទាំង
ឡាយ ដ៏សម្បូណ៌ (និង) អ្នកដែនទាំងនោះឲ្យលុះក្នុង
អំណាច (របស់យើងខ្ញុំ) តពីនោះមក លោកដ៏ចម្រើន
អាចធ្វើក្សត្រិយ៍ ១០១ ឲ្យជាចំណុះ (នៃយើងខ្ញុំបាន)។

បតីតាស្សុ មយំ ភោតោ, វទ តំ ភញ្ជ មិច្ឆសិ;
ហត្ថិយានំ អស្សរថំ, នារិយោ ច អលង្កតា;
និវេសនានិ រម្មានិ, មយំ ភោតោ ទទាមសេ ។

យើងខ្ញុំត្រេកអរនឹងលោកដ៏ចម្រើន លោកចង់
បានរតនៈ (ណា) ចូរទទួលយករតនៈនោះចុះ យើងខ្ញុំ

ប្រគេនយានដំរី រថសេះ ពួកនាងនារី ដែលប្រដាប់ស្រេច ទាំងលំនៅគួរឲ្យត្រេកអរទាំងឡាយដល់លោកដ៏ចម្រើន។

អថ វង្គេ វា មគធេ, មយំ ភោតោ ទទាមសេ;
អថ វា អស្សកាវន្តី, សុមនា ទម្ម តេ មយំ ។

មួយទៀត យើងខ្ញុំប្រគេនដែនអង្គៈ ឬមគធៈ ដល់លោកដ៏ចម្រើន មួយទៀត យើងខ្ញុំសប្បាយចិត្តប្រគេនដែនអស្សកៈ ឬដែនអវន្តីដល់លោក។

ឧបឌ្ឍំ វាបិ រជ្ជស្ស, មយំ ភោតោ ទទាមសេ;
សចេ តេ អត្ថោ រជ្ជេន, អនុសាស យទិច្ឆសិ ។

យើងខ្ញុំប្រគេនរាជ្យពាក់កណ្ដាល ដល់លោកដ៏ចម្រើន បើលោកត្រូវការដោយរាជ្យ លោកចង់បានរបស់ណា សូមត្រួតត្រារបស់នោះចុះ។

នន្ទបណ្ឌិតបានស្ដាប់ព្រះបន្ទូលនោះហើយ កាលបញ្ឈាក់នូវបំណងរបស់ខ្លួន ទើបពោលថា៖

**‘ន មេ អត្ថោបិ រដ្ឋេន, នគរេន ធនេន វា;**
**អថោបិ ជនបទេន, អត្ថោ មយ្ហំ ន វិជ្ជតិ ។**

អាត្មាភាព មិនត្រូវការដោយរាជ្យ ដោយនគរ ឬដោយទ្រព្យ ទាំងមិនត្រូវការដោយជនបទទេ។

រួចលោកសំណូមពរថា ប្រសិនបើ ព្រះអង្គមានសេចក្ដីស្រឡាញ់ពេញចិត្តនឹងអាត្មា សូមព្រះអង្គធ្វើតាមពាក្យអាត្មាចុះ រួចក៏ពោល ២ គាថាទៀតថា ៖

**ភោតោវ រដ្ឋេ វិជិតេ, អរញ្ញេ អត្ថិ អស្សមោ;**
**បិតា មយ្ហំ ជនេត្តី ច, ឧភោ សម្មន្តិ អស្សមេ ។**

ក្នុងព្រៃ ក្នុងដែន ជាអាណាខេត្តរបស់ព្រះអង្គដ៏ចម្រើនមានអាស្រមមួយ បិតាមាតារបស់អាត្មាភាពទាំងពីរនាក់ នៅក្នុងអាស្រមនោះ។

តេសាហំ  បុព្ពាចរិយេសុ, បុញ្ញំ ន លភាមិ តាតវេ;
ករន្តិ អព្ភារំ តត្ថ, សោណំ យាចេមុ សំវរំ ។

*អាត្មាភាពមិនបានធ្វើបុណ្យ ចំពោះបុព្វាចារ្យទាំងនោះ យើងធ្វើព្រះអង្គដ៏ចម្រើនឲ្យប្រសើរលើសលុប ឲ្យសូមនូវការរួបរួមជាមួយនឹងសោណបណ្ឌិតតាបស។*

*គ្រានោះ ព្រះរាជាក៏មានព្រះរាជឱង្ការថា ៖*

ករោមិ តេ តំ វចនំ, យំ មំ ភណសិ ព្រាហ្មណ;
ឯតញ្ច ខោ នោ អក្ខាហិ, កីវន្តោ ហោន្តុ យាចកា ។

*បពិត្រព្រាហ្មណ៍ ខ្ញុំធ្វើតាមពាក្យរបស់លោកដែលលោកពោលនឹងខ្ញុំ សូមលោកប្រាប់ហេតុនោះដល់យើងខ្ញុំ តើឲ្យពួកជនប៉ុន្មាននាក់ ជាអ្នកជួយអង្វរករ។*

*នន្ទបណ្ឌិតពោលថា ៖*

បរោសតំ ជានបទា, មហាសាលា ច ព្រាហ្មណា;

ឥមេ ច ខត្តិយា សព្ពេ, អភិជាតា យសស្សិនោ;
ករញ្ចុ រាជា មនោជោ, អលំ ហេស្សន្តិ យាចកា ។

ពួកគហបតីមហាសាលជាច្រើនរយ ពួកព្រាហ្មណ៍មហាសាលជាច្រើនរយ និងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិដ៏ខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចម្រើនទើបល្មមជាអ្នកជួយអង្វរករ។

គ្រានោះ ព្រះរាជាត្រាស់ថា ៖

ហត្ថី អស្សេ ច យោជេន្តុ, រថំ សន្នយ្ហ សារថិ;
អាពន្ធនានិ គណ្ហាថ, ធជានុស្សាបយន្តុធេ;
អស្សមំ តំ គមិស្សាមិ, យត្ថ សម្មតិ កោសិយោ ។

ពួកអ្នករក្សាដំរី ពួកអ្នករក្សាសេះ ចូរនាំគ្នាចាត់ចែងនូវពួកដំរីពួកសេះ ម្នាលសារថី អ្នកចូរជ្រាមរថ អ្នកទាំងឡាយ ចូរយកគ្រឿងប្រដាប់ សម្រាប់ចង (ឯដំរីសេះរថ) ជនទាំងឡាយ ចូរលើកទង់ជ័យ ត្រង់ដើង

ទង់ជ័យដែលតម្កល់លើរថ អញនឹងទៅកាន់អាស្រមជាទីនៅនៃកោសិយគោត្ត។

ព្រះសាស្តាកាលប្រកាសសេចក្ដីនេះ ទើបត្រាស់អភិសម្ពុទ្ធគាថានេះថា ៖

**តតោ ច រាជា ចាយាសិ, សេនាយ ចតុរង្គិនី;**
**អគមា អស្សមំ រម្មំ, យត្ថ សម្មតិ កោសិយោ ។**

លំដាប់ពីនោះមក ព្រះរាជាបានយាងទៅដោយសេនាប្រកបដោយអង្គ ៤ ទ្រង់ស្ដេចទៅកាន់អាស្រមជាទីរីករាយ ជាទីនៅនៃកោសិយគោត្ត។

(គាថានេះមានសេចក្ដីអធិប្បាយថា ៖)

ម្នាលភិក្ខុទាំងឡាយ លំដាប់ពីនោះ ព្រះបាទមនោជៈបាននាំស្ដេចទាំង ១០១ ព្រះអង្គ ហែហម

ដោយសេនាដ៏ច្រើន ឲ្យនន្ទបណ្ឌិតនាំមុខ ចេញចាក ព្រះនគរ យាងទៅ។

បទថា **ចតុរង្គិនី** (*សេនាប្រកបដោយអង្គ ៤*) គឺ សេនាប្រកបដោយអង្គ ៤ សូម្បីអន្តរាយដែលប្រព្រឹត្ត ទៅតាមផ្លូវ ក៏លោកពោលហើយយ៉ាងនេះ នន្ទបណ្ឌិត បញ្ចៀសភ្ញៀងឲ្យទៅជាមិនមានភ្ញៀង។ ព្រះរាជាកាល យាងទៅតាមផ្លូវ មួយអន្លើដោយកងពលប្រមាណ ២៤ អក្ខោភិនី នន្ទបណ្ឌិតបាននិម្មិតជាផ្លូវដ៏រាបស្មើ មានទទឹងប្រមាណ ៨ ឧសភៈ ហើយលោកក្រាលច្រម ខណ្ឌព្ធដ៏អាកាសអង្គុយពែនភ្នែនលើច្រមខណ្ឌនោះ ហែហាមដោយពលសេនា កាលសម្តែងកថាដ៏សមគួរ ដល់ធម៌ ជាមួយនឹងព្រះរាជាដែលគង់លើកដំរី ដែល គេប្រដាប់តាក់តែងយាងទៅហើយ លោករារាំង

បញ្ចៀសនូវអន្តរាយផ្សេងៗ មានត្រដាក់ក្តៅជាដើម ធ្វើដំណើរទៅ។

## សោណបណ្ឌិតជួបនឹងព្រះចាងមហោឆ:

គ្រានោះ ក្នុងថ្ងៃដែលនន្ទបណ្ឌិត និងពលសេនាមកដល់នោះ សោណបណ្ឌិតកំពុងពិចារណាថា ប្អូនប្រុសរបស់យើងបានចាកចេញទៅអស់ជាង ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃហើយ ឥឡូវនេះ តើលោកនៅទីណា។ កាលប្រមើលមើលដោយទិព្វចក្ខុ ក៏ឃើញនន្ទបណ្ឌិតនាំព្រះរាជា ១០១ មួយអន្លើដោយបរិវារ ប្រមាណ ២៤ អក្ខោភិនីមក បំណងនឹងសូមខមាទោសចំពោះយើង ក៏គិតថា ក៏កាលដែលពួកស្តេច និងបរិស័ទទាំងឡាយដែលបានឃើញបាដិហារ្យដ៏ច្រើននៃប្អូនប្រុសរបស់យើង ហើយមិនដឹងអានុភាពនៃយើង គប្បីនាំគ្នា

ពោលតិះដៀលយើង ហើយប្រាកដជាធ្លាក់ទៅកាន់អវិចីនរកមិនខានឡើយ (ដូច្នេះ) យើងនឹងសម្ដែងឥទ្ធិបាដិហារ្យឲ្យអ្នកទាំងនោះបានឃើញ ។ លោកក៏ដាក់ដងរែកក្នុងលំហអាកាស មិនឲ្យប៉ះស្មាដោយប្រមាណ ៤ ធ្នាប់ ហោះទៅតាមអាកាសក្បែរព្រះរាជាដើម្បីទៅដងទឹកអំពីអនោតត្តស្រះ។ នន្ទបណ្ឌិតកាលបានឃើញបងកំពុងនិមន្តមក មិនហ៊ាននឹងបង្ហាញខ្លួន ក៏បាត់ចាកទីអង្គុយភ្លាម ចូលទៅព្រៃហេមពាន្ត។

លំដាប់នោះ ព្រះបាទមនោជៈ កាលបានឃើញសោណបណ្ឌិតកំពុងនិមន្តមក ដោយភេទជាឥសីដែលគួរឲ្យរីករាយ ក៏ត្រាស់គាថាថា ៖

**កាស្ស កាខម្ពយោ កាជោ, វេហាសំ ចតុរង្គុលំ;**
**អំសំ អសម្ផុសំ ឯតិ, ឧទហារាយ គច្ឆតោ ។**

ជង់វែក ជាវិការៈនៃឈើក្តម្ពរបស់អ្នកណា ដែលទៅជង់ទឹក ហើយមិនប៉ះពាល់ស្មា ទៅលើអាកាស ចំនួន ៤ ធ្លាប់។

កាលព្រះរាជាត្រាស់សួរយ៉ាងនេះហើយ ព្រះមហាសត្វទើបពោល ២ គាថាថា ៖

អហំ សោណោ មហារាជ, តាបសោ សហិតព្វតោ;
ភរាមិ មាតាបិតរោ, រត្តិន្ទិវមតន្ទិតោ ។

បពិត្រមហារាជ អាត្មាភាពជាតាបសឈ្មោះសោណៈ ប្រកបដោយវត្ត មិនខ្ជិលច្រអូស ចិញ្ចឹមមាតាបិតា ទាំងយប់ទាំងថ្ងៃ។

វនេ ផលញ្ច មូលញ្ច, អាហរិត្វា ទិសម្បតិ;
បោសេមិ មាតាបិតរោ, បុព្ពេ កតមនុស្សរំ ។

បពិត្រព្រះអង្គជាម្ចាស់នៃទិស អាត្មាភាព រលឹកឃើញឧបការៈដែលមាតាបិតាធ្វើក្នុងកាលមុន ហើយក៏យកផ្លែឈើនិងមើមឈើក្នុងព្រៃ មកចិញ្ចឹមមាតាបិតា។

ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់មានសេចក្តីប្រាថ្នានឹងធ្វើសេចក្តីស្និទ្ធស្នាល ជាមួយតាបសនោះ ក៏ត្រាស់គាថាដទៃទៀតថា ៖

**ឥច្ឆាម អស្សមំ គន្តុំ, យត្ថ សម្មតិ កោសិយោ;**
**មគ្គំ នោ សោណ អក្ខាហិ, យេន គច្ឆេមុ អស្សមំ ។**

យើងខ្ញុំចង់នៅកាន់អាស្រម ជាទីនៅរបស់កោសិយគោត្ត បពិត្រព្រះសោណៈ សូមលោកម្ចាស់ប្រាប់ផ្លូវដល់យើង យើងនឹងទៅកាន់អាស្រម។

គ្រានោះព្រះមហាសត្វបាននិម្មិតផ្លូវទៅកាន់អាស្រមបទ ដោយអានុភាព របស់ខ្លួនរួចហើយ ក៏

ពោលគាថាថា ៖

**អយំ ឯកាបទី រាជ, យេនេតំ មេឃសន្និភំ;**
**គោវិឡារេហិ សញ្ឆន្នំ, ឯត្ថ សម្មតិ កោសិយោ ។**

បពិត្រព្រះរាជា ផ្លូវដើរចុះតែដើង ១ នេះ មានព្រៃមានពណ៌ដូចជាផ្ទៃមេឃ ដ៏ដេរដាសដោយដើមរលួសផ្អុងនុំះ ជាទីនៅរបស់កោសិយគោត្ត។

ព្រះគាថានេះមានសេចក្ដីអធិប្បាយថា ៖

បពិត្រមហារាជ នេះជាផ្លូវដើរចុះតែដើងមួយ ជាផ្លូវទៅដោយស្មង សូមព្រះអង្គយាងទៅតាមផ្លូវនេះចុះ កោសិយគោត្តជាបិតារបស់អាត្មាភាពតែងគង់អាស្រ័យនៅក្នុងទិសាភាគ ដែលប្រាកដមានព្រៃមានពណ៌ដូចជាផ្ទៃមេឃដ៏មីរដេរដាសដោយដើមរលួស

ផ្កុង កំពុងសំយុងចេញផ្កាវីកស្គុះស្គាយ អាស្រមនុ៎ះជារបស់កោសិយគោត្តនុ៎ះ។

ព្រះសាស្ដាកាលប្រកាសសេចក្ដីនោះ ទើបត្រាស់អភិសម្ពុទ្ធគាថាទាំងនេះថា ៖

**ឥទំ វត្វាន បក្កាមិ, តរមានោ មហាឥសិ;**
**វេហាសេ អន្តលិក្ខស្មឹ, អនុសាសិត្វាន ខត្តិយេ ។**

លុះមហាឥសីពោលពាក្យនេះទូលប្រាប់ពួកក្សត្រិយ៍ហើយ ប្រញាប់ប្រញាល់ចៀសចេញទៅ (កាន់ស្រះអនោតត្ត) តាមអាកាសវេហាស៍។

**អស្សមំ បរិមជ្ជិត្វា, បញ្ញបេត្វាន អាសនំ;**
**បណ្ណសាលំ បវិសិត្វា, បិតរំ បដិពោធយិ ។**

មហាឥសី ក៏បោសសម្អាតអាស្រម រៀបចំអាសនៈ ចូលទៅកាន់បណ្ណសាលាហើយជម្រាបបិតា

ឲ្យជ្រាបថា

ឥមេ អាយន្តិ រាជានោ, អភិជាតា យសស្សិនោ;
អស្សមា និក្ខមិត្វាន, និសីទ ត្វំ មហាឥសេ ។

បពិត្រមហាឥសី ព្រះរាជាទាំងនេះ មានជាតិខ្ពស់ មានយស យាងមក សូមព្រះបិតាចេញអំពីអាស្រមមកគង់ចាំទទួល។

តស្ស តំ វចនំ សុត្វា, តរមានោ មហាឥសិ;
អស្សមា និក្ខមិត្វាន, សទ្វារម្ហិ ឧបាវិសិ ។

មហាឥសីឮពាក្យនោះ របស់កូននោះហើយ ក៏ប្រញាប់ប្រញាលចេញអំពីអាស្រម មកអង្គុយជិតទ្វារ។

ព្រះគាថានេះមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ សោណឥសីនោះទៅកាន់អនោតត្តស្រះដោយរហ័ស ដងទឹកប្រើប្រាស់ ហើយ

ត្រឡប់មក យកទឹកចាក់ក្នុងក្អមនៅឯរោងសម្រាប់តម្កល់ទឹកប្រើប្រាស់ ទាំងដែលពួកស្ដេចទាំងនោះ មិនទាន់មកដល់អាស្រមផងឡើយ បានអប់ទឹកដោយផ្កាឈើក្នុងព្រៃទាំងឡាយ ដោយគិតថា មហាជននឹងផឹក រួចហើយក៏ទាញអំបោសមកបោសសម្អាតអាស្រម ក្រាលអាសនៈ រួចឲ្យបិតាបានជ្រាបដំណឹង។

ឯព្រះមាតារបស់ព្រះពោធិសត្វ ក៏អង្គុយនៅកន្លែងទាបដ៏សមគួរមួយខាងក្រោយតាបសជាបិតា។ ព្រះមហាសត្វអង្គុយលើអាសនៈទាបក្បែរនោះដែរ។ ចំណែកឯនន្ទបណ្ឌិត កាលដែលព្រះពោធិសត្វទៅដងទឹកពីអនោតត្តស្រះយកមកអាស្រមនោះ ក៏និមន្តទៅកាន់សំណាក់ព្រះរាជា តាំងបន្ទាយនៅទីជិតអាស្រម។ គ្រានោះ ព្រះរាជាទ្រង់ស្រង់ទឹក ហើយទ្រង់

ប្រដាប់តាក់តែងដោយគ្រឿងអលង្ការគ្រប់យ៉ាង មាន ស្តេច ១០១ ជាបរិវារ នាំនន្ទបណ្ឌិតចូលទៅកាន់ អាស្រម ដើម្បីសូមខមាទោសព្រះពោធិសត្វ ដោយ ប្រការដ៏លើសលុប ដោយលម្អនៃសិរីដ៏អស្ចារ្យ។ គ្រា នោះ បិតារបស់ព្រះពោធិសត្វកាលបានឃើញព្រះ រាជាកំពុងយាងមកយ៉ាងនោះ ក៏សួរទៅព្រះពោធិសត្វ ព្រះពោធិសត្វក៏ប្រាប់ដល់ព្រះបិតា។

ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើប ត្រាស់ព្រះគាថាទាំងឡាយនេះថា ៖

**តញ្ច ទិស្វាន អាយន្តំ, ជលន្តំរិវ តេជសា;**
**ខត្យសង្ឃបរិព្យូឡ្ហំ, កោសិយោ ឯតទព្រវិ។**

កោសិយគោត្តតាបស បានឃើញស្តេចនោះ ដូច ជារុងរឿងដោយតេជះ មានពួកក្សត្រិយ៍ហែហម កំពុង

យាងមក ហើយបានពោលពាក្យនេះថា

កស្ស ភេរី មុទិង្គា ច, សង្ខា បណវទិណ្ឌិមា;
បុរតោ បដិបន្នានិ, ហាសយន្តា រថេសភំ ។

ស្គរ សម្ភោរ ស័ង្ខ ស្គរតូច និងមហោរធឹករបស់អ្នកណាញុំាងស្តេចជាបុគ្គលប្រសើរលើរថ ឲ្យរីករាយទៅខាងមុខ។

កស្ស កញ្ចនបដ្ដេន, បុថុនា វិជ្ជុវណ្ណិនា;
យុគំ កលាបសន្នទ្ធោ, កោ ឯតិ សិរិយា ជលំ ។

(ទីបំផុតថ្វាស) នៃអ្នកណា (បិទបាំង) ដោយដំបារមាសដ៏ធំ មានពណ៌ ដូចជាផ្ទេកបន្ទោរ ប្រុសកំលោះណា សៀតបំពង់ព្រួញ រុងរឿងដោយសិរីដោយដើរមក។

ឧក្កាមុខបហដ្ឋំវ, ខទិរង្គារសន្និភំ;

**មុខញ្ច រុចិរា ភាតិ, កោ ឯតិ សិរិយា ជលំ ។**

*អ្នកណាមានមុខរុងរឿងភ្លឺចាំង ដូចជាមាសភ្លឺចិញ្ចាចត្រង់មាត់បាវ ស្រដៀងនឹងរងើកភ្លើងនៃឧសគគីរ រុងរឿងដោយសិរី ហើយដើរមក។*

**កស្ស បគ្គហិតំ ឆត្តំ, សសលាកំ មនោរមំ;**
**អាទិច្ចរំសាវរណំ, កោ ឯតិ សិរិយា ជលំ ។**

*អ្នកណា បាំងឆត្រព្រមទាំងឆ្អឹង ជាទីរីករាយនៃចិត្ត ការពាររស្មីព្រះអាទិត្យ អ្នកណារុងរឿងដោយសិរី ហើយដើរមក។*

**កស្ស អង្គំ បរិគ្គយ្ហ, វាឡពីជនិមុត្តមំ;**
**ចរន្តិ វរបុញ្ញស្ស, ហត្ថិក្ខន្ធេន អាយតោ ។**

*ពួកជនបិទបាំងជុំវិញខ្លួន នៃអ្នកណា ដែលមានបុណ្យដ៏ប្រសើរ កំពុងជិះលើកនៃដំរី ដោយផ្ចិតពោម*

*សត្វដ៏ឧត្តម ហើយដើរទៅ។*

កស្ស សេតានិ ឆត្តានិ, អាជានីយា ច វម្មិតា;
សមន្តា បរិកិរេន្តិ, កោ ឯតិ សិរិយា ជលំ ។

*ពួកឆត្រសនិងពួកអាជានេយ្យ ប្រដាប់ដោយ*
*គ្រោះខ្នាន់ខ្នាប់ជុំវិញ នៃអ្នកណា អ្នកណារុងរឿង*
*ដោយសិរីហើយដើរមក។*

កស្ស ឯកសតំ ខត្យា, អនុយន្តា យសស្សិនោ;
សមន្តានុបរិយន្តិ, កោ ឯតិ សិរិយា ជលំ ។

*ពួកក្សត្រិយ៍មួយរយមួយ សុទ្ធតែមានយសជា*
*ស្តេចចំណុះ ដើរហែហមជុំវិញនៃអ្នកណា អ្នកណា*
*រុងរឿងដោយសិរី ដើរមក។*

ហត្ថិ អស្សរថ បត្តិ, សេនា ច ចតុរង្គិនី;
សមន្តានុបរិយន្តិ, កោ ឯតិ សិរិយា ជលំ ។

ពួកសេនាប្រកបដោយអង្គ ៤ គឺដំរី ១ សេះ ១ រថ ១ ពលថ្មើរជើង ១ ដើរហែហមជុំវិញ (នៃអ្នកណា) អ្នកណារុងរឿងដោយសិរី ដើរមក។

កស្សេសា មហតី សេនា, បិដ្ឋិតោ អនុវត្តតិ;
អក្ខោភណី អបរិយន្តា, សាគរស្សេវ ឩមិយោ ។

សេនាដ៏ធំនេះ មិនមានអ្នកណាមួយឲ្យរំកើបបាន មិនមានទីបំផុត ដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃអ្នកណា។

រាជាភិរាជា មនោជោ, ឥន្ទោវ ជយតំ បតិ;
នន្ទស្សជ្ឈាវរំ ឯតិ, អស្សមំ ព្រហ្មចារិនំ ។

ព្រះបាទមនោជៈ ជាព្រះរាជាប្រសើរជាងពួកព្រះរាជា ដូចជា ព្រះឥន្ទ្រជាធំជាងពួកទេវតា ក្នុងឋានត្រៃត្រិង្ស ដែលមានជ័យជម្នះ បានដល់នូវភាពជា

បរិស័ទនៃនន្ទតាបស មកកាន់អាស្រមនៃពួកព្រហ្មចារីបុគ្គល (ដើម្បីខមាទោសនឹងយើង)។

តស្សេសា មហាតី សេនា, បិដ្ឋិតោ អនុវត្តតិ;
អក្ខោភណី អបរិយន្តា, សាគរស្សេវ ឩមិយោ ។

សេនាដ៏ធំនេះ មិនមានអ្នកណាមួយ ឲ្យរំភើបបាន មិនមានទីបំផុតដូចជារលក នៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃព្រះបាទមនោជៈនោះ។

ព្រះសាស្តាត្រាស់បន្តទៀតថា ៖

អនុលិត្តា ចន្ទនេន, កាសិកុត្តមធារិនោ;
សព្ពេ បញ្ជលិកា ហុត្វា, ឥសីនំ អជ្ឈុបាគមុំ ។

ពួកព្រះរាជាទាំងអស់ លាបស្រឡាបដោយខ្លឹមចន្ទន៍ ទ្រង់កាសិកពស្ត្រដ៏ឧត្តម បានផ្គងអញ្ជលីចូលទៅរកពួកឥសី។

គាថានេះមានសេចក្ដីថា ៖

ម្នាលភិក្ខុទាំងឡាយ ព្រះរាជាទាំងនោះសូម្បីទាំងអស់  លាបស្រឡាបដោយខ្លឹមចន្ទន៍ដ៏ក្រអូប ទ្រង់កាសិកពស្ត្រដ៏ឧត្ដម ជាអ្នកមានអញ្ជលីដាក់លើសិរសា ដើរចូលទៅកាន់សំណាក់ពួកឥសី។

លំដាប់នោះ ព្រះបាទមនោជៈថ្វាយបង្គំឥសី ហើយគង់ក្នុងទីដ៏សមគួរ កាលទ្រង់ធ្វើបដិសណ្ឋារកិច្ច ទើបត្រាស់២ព្រះគាថាថា ៖

**កច្ចិ នុ ភោតោ កុសលំ, កច្ចិ ភោតោ អនាមយំ;**
**កច្ចិ ឧញ្ឆេន យាបេថ, កច្ចិ មូលផលា ពហូ ។**

លោកដ៏ចម្រើនមានសេចក្ដីសុខស្រួលទេឬ លោកដ៏ចម្រើនមានអនាម័យទេឬ លោកទាំងឡាយ

ចិញ្ចឹមជីវិត ដោយការស្វែងរកឬ មើមឈើនិងផ្លែឈើមានច្រើនដែរឬ។

កច្ចិ ឌំសា មកសា ច, អប្បមេវ សរីសបា;
វនេ វាឡមិគាកិណ្ណេ, កច្ចិ ហឹសា ន វិជ្ជតិ ។

ពួករបោម មូស ពស់ មានតិចតួចដែរឬ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនបៀតបៀនទេឬ។

តពីនោះទៅ ជាគាថាពោលតបរបស់តាបសទាំង២នោះថា ៖

កុសលញ្ចេវ នោ រាជ, អថោ រាជ អនាមយំ;
អថោ ឧញ្ឆេន យាបេម, អថោ មូលផលា ពហូ ។

បពិត្រព្រះរាជា អាត្មាភាព មានសេចក្ដីស្រួលទេ បពិត្រព្រះរាជា មួយទៀត អាត្មាភាព មិនមានសេចក្ដីឈឺចាប់ទេ អាត្មាភាពចិញ្ចឹមជីវិតដោយការស្វែងរក

(ផលាផល) ស្រួលទេ ទាំងមើមឈើនិងផ្លែឈើក៏មាន
ច្រើន។

អថោ ឌំសា មកសា ច, អប្បមេវ សរីសបា;
វនេ វាឡមិគាកិណ្ណេ, ហិំសា មយ្ហំ ន វិជ្ជតិ ។

មួយទៀត ពួករបោម មូស ពស់ ក៏មានតិចតួច ទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ ក៏មិន បៀតបៀនអាត្មាភាពទេ។

ពហូនិ វស្សបូគានិ, អស្សមេ សម្មតំ ឥជ;
នាភិជានាមិ ឧប្បន្នំ, អាពាធំ អមនោរមំ ។

អាត្មាភាព មកនៅក្នុងអាស្រមនេះ អស់ប្រជុំនៃ ឆ្នាំជាច្រើន មិនដែលស្គាល់អាពាធ មិនជាទីត្រេកអរនៃ ចិត្ត កើតឡើងទេ។

ស្វាគតំ តេ មហារាជ, អថោ តេ អទុរាគតំ;

ឥស្សរោសិ អនុប្បត្តោ, យំ ឥធត្ថិ បវេទយ ។

បពិត្រមហារាជ ព្រះអង្គយាងមកល្អហើយ មួយទៀត ព្រះអង្គមិនមែនយាងមកអាក្រក់ទេ ព្រះអង្គជាឥស្សរៈ យាងមកដល់ហើយ វត្ថុមានក្នុងទីនេះ សូមព្រះអង្គមានព្រះបន្ទូល។

តិន្ទុកានិ បិយាលានិ, មធុកេ កាសុមារិយោ;
ផលានិ ខុទ្ទកប្បានិ, ភុញ្ជ រាជ វរំ វរំ ។

បពិត្រព្រះរាជា សូមព្រះអង្គសោយផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែស្រគំ ផ្លែមាក់ដោក មានរសឆ្ងាញ់ពិសាដូចជាទឹកឃ្មុំ។

ឥទម្បិ បានីយំ សីតំ, អាភតំ គិរិគព្ភរា;
តតោ បិវ មហារាជ, សចេ ត្វំ អភិកង្ខសិ ។

ទឹកត្រជាក់នេះ អាត្មាភាព បានដងមក អំពី

ជ្រោះភ្នំ បពិត្រមហារាជ សូមព្រះអង្គសោយទឹកនោះចុះ ប្រសិនបើទ្រង់ត្រូវការ។

(ព្រះរាជាត្រាស់ថា ៖)

បដិគ្គហិតំ យំ ទិន្នំ, សព្ពស្ស អគ្ឃិយំ កតំ;
ននុស្សាបិ និសាមេថ, វចនំ សោ បវក្ខតិ ។

របស់ណាដែលលោកឲ្យហើយ (របស់នោះ) ឈ្មោះថា យើងខ្ញុំទទួលហើយ ទាំងបានធ្វើឲ្យជាជំនូនដល់ជនទាំងពួង លោកទាំងឡាយ ចូរស្តាប់ពាក្យនន្ទបណ្ឌិតតាបស លោកនឹងនិយាយឥឡូវនេះ។

អជ្ឈាវរម្ហា នន្ទស្ស, ភោតោ សន្តិកមាគតា;
សុណាតុ ភវំ វចនំ, នន្ទស្ស បរិសាយ ច ។

ពួកយើងជាបរិស័ទនៃនន្ទបណ្ឌិតតាបស បានមកកាន់សម្នាក់នៃលោកដ៏ចម្រើន សោណបណ្ឌិតដ៏

*ចម្រើនចូរស្តាប់ពាក្យ នៃខ្ញុំផង នៃបរស័ទរបស់នន្ទ-បណ្ឌិតតាបសផង។*

## ឆន្ទបណ្ឌិតសូមខមាទោសសោណបណ្ឌិត

*កាលព្រះរាជាត្រាស់យ៉ាងនេះហើយ នន្ទ-បណ្ឌិតក៏ក្រោកចាកអាសនៈថ្វាយបង្គំមាតាបិតា និង បងប្រុស កាលនិយាយជាមួយនឹងបរិស័ទរបស់ខ្លួន ក៏ពោលថា ៖*

**បរោសតំ ជានបទា, មហាសាលា ច ព្រាហ្មណា;**
**ឥមេ ច ខត្តិយា សព្ពេ, អភិជាតា យសស្សិនោ;**
**ភវញ្ច រាជា មនោជោ, អនុមញ្ញន្តុ មេ វចោ។**

*ពួកគហបតីមហាសាលជាងមួយរយ ពួកព្រាហ្មណ៍មហាសាលជាងមួយរយ និងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិខ្ពស់ មានយសនេះ ទាំង*

*ព្រះបាទមនោជៈដ៏ចម្រើនសូមជ្រាបតាមសំដីរបស់អាត្មាភាពចុះ។*

យេ ច សន្តិ  សមីតារោ, យក្ខានិ ឥធ មស្សមេ;
អរញ្ញេ ភូតភព្យានិ, សុណន្តុ វចនំ មម ។

*ពួកជនដែលមកជួបជុំគ្នា ពួកយក្ស ពួកភូតនិង ទេវតា ក្មេងមានក្នុងអាស្រមក្នុងព្រៃនេះ ចូរស្ដាប់នូវពាក្យរបស់អាត្មា។*

នមោ កត្វាន ភូតានំ, ឥសិំ វក្ខាមិ សុព្ពតំ;
សោ ត្យាហំ ទក្ខិណោ ពាហុ, តវ កោសិយ សម្មតោ ។

*អាត្មាធ្វើនមស្ការដល់ពួកភូតហើយ នឹងនិយាយចំពោះឥសី (ឈ្មោះសោណបណ្ឌិត) ដែលមានវត្តល្អថា ខ្ញុំនោះហើយដែលកោសិយគោត្តសន្មតថា ជាដើមដៃស្តាំ របស់លោក។*

បិតរំ មេ ជនេត្តិញ្ច, កត្តុកាមស្ស មេ សតោ;
វីរ បុញ្ញមិទំ ឋានំ, មា មំ កោសិយ វារយ ។

បពិត្រអ្នកមានព្យាយាម ការទំនុកបម្រុងមាតាបិតានេះ ជាបុណ្យរបស់ខ្ញុំ ដែលជាអ្នកប្រាថ្នាចិញ្ចឹមមាតានិងបិតារបស់ខ្ញុំ បពិត្រព្រះកោសិយៈ សូមលោកកុំឃាត់ខ្ញុំឡើយ។

សព្ភិ ហេតំ ឧបញ្ញាតំ, មមេតំ ឧបនិស្សជ;
ឧដ្ឋានចារិចរិយាយ, ទីឃរត្តំ តយា កតំ;
មាតាបិតូសុ បុញ្ញានិ, មម លោកទទោ ភវ ។

ការទំនុកបម្រុងមាតាបិតានុ៎ះ ពួកសប្បុរសបានដឹងហើយ សូមលោកលះនូវការទំនុកបម្រុងមាតាបិតានេះឲ្យដល់ខ្ញុំ លោកបានធ្វើ (កុសល) ដោយការខ្នះខ្នែងនឹងការបម្រើយូរយារណាស់មកហើយ (ឥឡូវ

នេះ ខ្ញុំចង់ធ្វើ បុណ្យទាំងឡាយ ដល់មាតានិងបិតា សូមលោកប្រគល់សួគ៌ទេវលោកដល់ខ្ញុំ។

តថេវ សន្តិ មនុជា, ធម្មេ ធម្មបទំ វិទូ;
មគ្គោ សគ្គស្ស លោកស្ស, យថា ជានាសិ ត្វំ ឥសេ ។

បពិត្រឥសី លោកដឹងផ្លូវទៅកាន់សួគ៌ទេវលោក យ៉ាងណា ពួកមនុស្សក៏ដឹងចំណែកធម៌ ក្នុងធម៌ ក៏ យ៉ាងនោះដែរ។

ឧដ្ឋានចារិចរិយាយ, មាតាបិតុសុខាវហំ;
តំ មំ បុញ្ញា និវារេតិ, អរិយមគ្គាវរោ នរោ ។

កិរិយានាំមកនូវសេចក្ដីសុខដល់មាតាបិតា ដោយការខ្នះខ្នែងនឹងការបម្រើ ឥឡូវនេះ ជន (សោណ-បណ្ឌិត) ហាមឃាត់ខ្ញុំនោះ ចាកបុណ្យ ឈ្មោះថាជាអ្នករារាំងផ្លូវដ៏ប្រសើរ (បានសួគ៌)។

កាលនន្ទបណ្ឌិតពោលយ៉ាងនេះហើយ ព្រះមហាសត្វកាលញ៉ាំងជនទាំងអស់ឲ្យបានឮ ដោយពាក្យថា ពាក្យរបស់តាបសនេះគឺពួកយើងបានស្តាប់ហើយ តែឥឡូវនេះ ចូរអ្នកទាំងឡាយស្តាប់ពាក្យរបស់ខ្ញុំវិញ ទើបពោលថា ៖

សុណន្តុ ភោន្តោ វចនំ, ភាតុរជ្ឈាវរា មម;
កុលវំសំ មហារាជ, គោរវំ បរិហាបយំ;
អធម្មចារី ជេដ្ឋេសុ, និរយំ សោបបជ្ជតិ ។

លោកដ៏ចម្រើនទាំងឡាយ ដែលជាបរិស័ទនៃប្អូនរបស់ខ្ញុំ សូមស្តាប់ពាក្យរបស់ខ្ញុំ បពិត្រមហារាជ អ្នកណា មិនប្រព្រឹត្តធម៌ ចំពោះបុគ្គលជាច្បងទាំងឡាយ ញ៉ាំងប្រវេណីពីបុរាណឲ្យសាបសូន្យ អ្នកនោះរមែងទៅកើតក្នុងនរក។

យេ ច ធម្មស្ស កុសលា, ចោរាណស្ស ទិសម្បតិ;
ចារិត្តេន ច សម្បន្នា, ន តេ គច្ឆន្តិ ទុគ្គតឹ ។

*បពិត្រព្រះអង្គជាម្ចាស់នៃទិស ពួកជនណាឈ្លាសវៃក្នុងក្នុងធម៌ (ជេដ្ឋាបចាយនធម៌) ជាប្រវេណីអំពីបុរាណ ព្រមទាំងបរិបូណ៌ដោយសណ្ដាប់ធ្នាប់ ពួកជននោះរមែងមិនទៅកាន់ទុគ្គតិទេ។*

មាតាបិតា ច ភាតា ច, ភគិនី ញាតិពន្ធវា;
សព្ពេ ជេដ្ឋស្ស តេ ភារា, ឯវំ ជានាហិ ភារធ ។

*បពិត្រព្រះអង្គជាអ្នកទ្រទ្រង់នូវបន្ទុក (ដែន) សូមព្រះអង្គជ្រាបយ៉ាងនេះថា មាតាបិតា បងប្អូនប្រុសស្រី ញាតិនិងផៅពង្សទាំងអស់នោះ ជាភារៈរបស់កូនច្បង។*

អាទិយិត្វា គរុំ ភារំ, នារិគោ វិយ ឧស្សហោ;

**ធម្មញ្ញុ ឆប្បមជ្ឈាមិ, ជេដ្ឋោ ចស្មិ រថេសភ ។**

*បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ អាត្មាភាពដូចជានាយសំពៅអាចនាំយកនូវភារៈដ៏ធ្ងន់ អាត្មាភាពពុំប្រមាទនូវជេដ្ឋាបចាយនធម៌ទេ ព្រោះអាត្មាភាពជាច្បង។*

*ព្រះរាជាទាំងអស់បានស្តាប់ពាក្យនោះហើយ ទ្រង់មានព្រះទ័យរីករាយត្រាស់ថា យើងបានដឹងក្នុងថ្ងៃនេះថា បានឮថា ភារៈចិញ្ចឹមមាតាបិតាជាភារៈរបស់កូនច្បង ដូច្នេះ ក៏ចោលនន្ទបណ្ឌិត នាំគ្នាមកអង្គុយចោមជុំព្រះមហាសត្វ កាលសរសើរសោណ-បណ្ឌិត ក៏ត្រាស់ ២ គាថាថា ៖*

**អធិគមា តមេ ញាណំ, ជាលំវ ជាតវេទតោ;**
**ឯវមេវ នោ ភវំ ធម្មំ, កោសិយោ បាវិទំសយិ ។**

ពួកយើងបានញាណដូចបុគ្គលបានអណ្ដាតភ្លើងអំពីភ្លើងក្នុងទីងងឹត កោសិយតាបសដ៏ចម្រើនបានផ្ទុះបញ្ចាំងធម៌ដល់ពួកយើង យ៉ាងនេះឯង។

យថា ឧទយមាទិច្ចោ, វាសុទេវោ បភង្ករោ;
បាណីនំ បវិទំសេតិ, រូបំ កល្យាណាបាបកំ;
ឯវមេវ នោ ភវំ ធម្មំ, កោសិយោ បវិទំសយិ ។

ព្រះអាទិត្យដែលបំភ្លឺនូវទ្រព្យ ធ្វើពន្លឺកាលរះឡើង តែងផ្ទុះបញ្ចាំងនូវរូបល្អ អាក្រក់ ដល់សត្វទាំងឡាយយ៉ាងណា កោសិយៈដ៏ចម្រើនបានផ្ទុះបញ្ចាំងនូវធម៌ដល់ពួកយើង ក៏យ៉ាងនោះដែរ។

ព្រះមហាសត្វទម្លាយសេចក្ដីជ្រះថ្លាក្នុងនន្ទបណ្ឌិតដែលមានអស់កាលប្រមាណប៉ុណ្ណោះ ឲ្យមកកាន់យកនូវកថារបស់ខ្លួន ធ្វើឲ្យព្រះរាជាសូម្បីទាំង

អស់ ឲ្យសម្ទឹងមកមើលមុខរបស់ខ្លួន ដោយកម្លាំងនៃញាណ។ គ្រានោះ នន្ទបណ្ឌិតគិតថា បងប្រុសរបស់យើងជាបណ្ឌិតឆ្លៀវឆ្លាស ជាធម្មកថិក បានបំបែកព្រះរាជាសូម្បីទាំងអស់នេះឲ្យមកជាបក្សពួករបស់ខ្លួន លើកទុកតែបងប្រុសនេះម្នាក់ចេញ គ្មានបុគ្គលដទៃណាជាទីពឹងអាស្រ័យនៃយើងបានទៀតទេ យើងមានតែអង្វរបងប្រុសនេះឯងតែម៉្យាងចុះ ទើបពោលគាថាដូច្នេះថា ៖

**ឃរំ មេ យាចមានស្ស, អញ្ជលឹ នាវពុជ្ឈថ;**
**តវ បទ្ធចរោ ហោស្សំ, វុដ្ឋិតោ បរិចារកោ ។**

កាលបើខ្ញុំអង្វរយ៉ាងនេះហើយ លោកនៅតែមិនទទួលអញ្ជលី ខ្ញុំនឹងជាអ្នកប្រព្រឹត្តតាមពាក្យ ជាអ្នកប្រឹងបម្រើលោក។

គាថានេះ មានសេចក្តីអធិប្បាយថា ៖

កាលដែលខ្ញុំអង្វរលោកដ៏ចម្រើនយ៉ាងនេះ ហើយលោកនៅតែមិនអើពើ គឺថាមិនទទួលនូវអញ្ជលីដែលខ្ញុំផ្គងហើយដើម្បីខមាទោសទេ សូមលោកដ៏ចម្រើនបម្រើមាតាបិតាតែម្យ៉ាងចុះ ចំណែកខ្ញុំនឹងជាអ្នកប្រព្រឹត្តតាមពាក្យគឺធ្វើសេចក្តីខ្វល់ខ្វាយចំពោះលោក ខ្ញុំនឹងក្រោកហើយដោយភាពមិនខ្ជិលច្រអូសអស់យប់និងថ្ងៃទំនុកបម្រុងបម្រើលោកដ៏ចម្រើនវិញ។

តាមប្រក្រតីព្រះមហាសត្វ នឹងរកទោសកំហុសឬចងពៀរវេរាចំពោះនន្ទបណ្ឌិតមិនមានសោះឡើយ តែកាលដែលលោកពោលនូវពាក្យធ្ងន់ៗយ៉ាងនេះដោយអំណាចការសង្កត់សង្កិន ដើម្បីឲ្យលះបង់នូវមានះប៉ុណ្ណោះ ពេលនេះ លោកបានស្តាប់ហើយនូវ

ពាក្យរបស់នន្ទបណ្ឌិតនោះ ក៏មានចិត្តត្រេកអរ ញុំាងចិត្តឲ្យជ្រះថ្លាក្នុងនន្ទបណ្ឌិតនោះ ក៏ពោលថា ឥឡូវនេះយើងអត់ទោសឲ្យដល់ឯង ឯងនឹងបានដើម្បីទំនុកបម្រុងមាតាបិតាចុះ កាលចង់ប្រកាសគុណរបស់នន្ទ-បណ្ឌិត លោកក៏ពោលគាថាថា ៖

**អទ្ធា នន្ទ វិជានាសិ, សទ្ធម្មំ សព្ភិ ទេសិតំ;**
**អរិយោ អរិយសមាចារោ, ពាឡ្ហំ ត្វំ មម រុច្ចសិ ។**

ម្នាលនន្ទ អ្នកស្គាល់ច្បាស់នូវព្រះសទ្ធម្មដែលពួកសប្បុរស សំដែងហើយមែន អ្នកជាមនុស្សល្អ មានឫកពារល្អ ត្រូវចិត្តយើងហើយ។

**កវន្តំ វទាមិ ភោតិញ្ញ, សុណាថ វចនំ មម;**
**នាយំ ភារោ ភារមតោ, អហុ មយ្ហំ កុនាចនំ ។**

ខ្ញុំសូមនិយាយនឹងបិតាដ៏ចម្រើន នឹងមាតាដ៏ចម្រើន សូមលោកទាំងឡាយស្តាប់ពាក្យរបស់ខ្ញុំ ភារៈនេះមិនមែនគ្រាន់តែជាភារៈរបស់ខ្ញុំក្នុងកាលម្តងៗ ទេៗ

តំ មំ ឧបដ្ឋិតំ សន្តំ, មាតាបិតុសុខាវហំ;
ឆន្ទោ អជ្ឈាវរំ កត្វា, ឧបដ្ឋានាយ យាចតិ ។

នន្ទៈធ្វើនូវខ្ញុំដែលជាអ្នកបម្រើ នាំមកនូវសេចក្តីសុខដល់មាតានិងបិតានោះ ឲ្យជាធំហើយសូមដើម្បីការបម្រើដែរៗ

យោ វេ ឥច្ឆតិ កាមេន, សន្តានំ ព្រហ្មចារិនំ;
ឆន្ទំ ឯកំ វរេ ឯកោ, តាំ ឆន្ទោ ឧបតិដ្ឋតុ ។

បណ្តា (មាតានិងបិតា) ជាព្រហ្មចារី បើលោកណាម្នាក់ចង់បាន សូមលោកទទួលយក នន្ទៈ តាមប្រាថ្នាចុះ តើឲ្យនន្ទៈបម្រើលោកណាៗ

# មាតាព្រះពោធិសត្វឲ្យនន្ទបម្រើ

គ្រានោះ មាតាព្រះមហាសត្វក្រោកចាកអាសនៈ ពោលថា នែសោណបណ្ឌិតកូន ប្អូនរបស់កូនព្រាត់ទៅយូរហើយ ម៉ែក៏មិនហ៊ានដើម្បីសូមនូវកូននន្ទនោះ ដែលមកហើយអំពីទីឆ្ងាយយ៉ាងនេះទេ ព្រោះថាយើងទាំងឡាយអាស្រ័យនឹងកូន ប៉ុន្តែឥឡូវនេះ ពួកយើងគឺកូនអនុញ្ញាតហើយ ម៉ែគួរតែបានឱបកូននន្ទនុ៎ះ ដែលជាព្រហ្មចារីដោយដៃទាំងពីរ ហើយថើបត្រង់ក្បាល កាលប្រកាសសេចក្ដីនោះ ទើបពោលគាថាថា ៖

**តយា តាត អនុញ្ញាតា, សោណ តំ និស្សិតា មយំ;**
**ឧបឃាតុំ លភេ នន្ទំ, មុទ្ធនិ ព្រហ្មចារិនំ ។**

*នៃសោណៈកូន យើងអាស្រ័យនឹងអ្នក អ្នកអនុញ្ញាតហើយ គួរបានដើម្បីចូលទៅថើបក្បាលនន្ទៈជាព្រហ្មចារីៗ*

*គ្រានោះ ព្រះមហាសត្វតបថា បពិត្រអ្នកម្ដាយបើដូច្នោះ ខ្ញុំអនុញ្ញាតអ្នកម៉ែឲ្យទៅ ចូរឱបនូវនន្ទជាកូនហើយថើបក្បាល ដើម្បីរម្ងាប់សេចក្ដីសោកក្នុងចិត្តរបស់អ្នកម៉ែចុះៗ នាងក៏ស្ទុះទៅកាន់សំណាក់កូនប្រុសពៅហើយ ឱបនូវនន្ទបណ្ឌិតក្នុងកណ្ដាលបរិស័ទនោះឯង នាងថើបក្បាលញក់ញី ដើម្បីរម្ងាប់សេចក្ដីសោកក្នុងចិត្តហើយរៀបរាប់ប្រាប់មហាសត្វថា ៖*

**អស្សត្ថស្សេវ តរុណំ, បវាឡំ មាលុតេរិតំ;**
**ចិរស្សំ ឧន្ទំ ទិស្វាន, ហទយំ មេ បវេជតិ ។**

ដួងហឫទ័យរបស់ម្ដាយរំជួល ព្រោះខានឃើញនន្ទៈអស់កាលយូរហើយ ដូចជា ស្មឹកខ្ចីរបស់អស្សត្ថព្រឹក្ស ដែលត្រូវខ្យល់បក់។

យទា សុត្តាបិ សុបិនេ, នន្ទំ បស្សាមិ អាគតំ;
ឧទគ្គា សុមនា ហោមិ, នន្ទោ នោ អាគតោ អយំ ។

វេលាណា ម្ដាយដេកលក់ យល់សប្ដិឃើញនន្ទៈមក ក៏មានចិត្តត្រេកអរ មានចិត្តរីករាយ (ដោយគិតថា) នន្ទៈរបស់យើងនេះ មកហើយ។

យទា ច បដិពុជ្ឈិត្វា, នន្ទំ បស្សាមិ នាគតំ;
ភិយ្យោ អាវិសតី សោកោ, ទោមនស្សញ្ចនប្បកំ ។

វេលាណាម្ដាយភ្ញាក់ឡើង មិនឃើញនន្ទៈមកទេ សេចក្ដីសោកនិងទោមនស្សជាច្រើន រឹងរឹតតែបណ្ដាលឡើង។

សាហំ អជ្ជ ចិរស្សម្បិ, ឧទ្ទិំ បស្សាមិ អាគតំ;
កន្តុច្ច មយ្ហញ្ច បិយោ, ឧទ្ទោ នោ ចារិសី ឃរំ ។

*យូរណាស់ហើយ ស្រាប់តែក្នុងថ្ងៃនេះ ម្តាយនោះឃើញនន្ទះមកដល់ នន្ទះជាទីស្រឡាញ់នៃស្វាមីរបស់ម្តាយផង នៃម្តាយផង បានចូលមកកាន់ផ្ទះរបស់ពួកយើង។*

បិតុបិ ឧទ្ទោ សុប្បិយោ, យំ ឧទ្ទោ ឧប្បវសេ ឃរា;
លកត្វ តាត ឧទ្ទោ តំ, មំ ឧទ្ទោ ឧបតិដ្ឋតុ ។

*នន្ទះជាទីស្រឡាញ់ក្រៃលែងរបស់បិតា កុំឲ្យនន្ទះទៅប្រាសចេញអំពីផ្ទះ នៃកូន ឯនន្ទះ (ចង់បានអ្នកណា) ចូរបានអ្នកនោះចុះ នន្ទះចូរបម្រើនូវអញចុះ។*

# សោណបណ្ឌិតបរិយាយគុណមាតា

*ព្រះមហាសត្វ ទទួលតាមពាក្យម្ដាយថា ចូរយ៉ាងហ្នឹងចុះ ហើយឲ្យឱវាទទៅនន្ទបណ្ឌិតថា នែនន្ទ ចំណែកជាចម្បងគឺប្អូនបានហើយ ធម្មតាម្ដាយមានគុណដែលគេធ្វើបានដោយកម្រ ចូរប្អូនកុំប្រមាទ ទំនុកបម្រុងគាត់ចុះ កាលប្រកាសនូវគុណនៃមាតា បានពោល ២ គាថាថា ៖*

**អនុកម្បិកា បតិដ្ឋា ច, បុព្វេ រសទទី ច នោ;**
**មគ្គោ សគ្គស្ស លោកស្ស, មាតា តំ វរតេ ឥសេ ។**

*ម្នាលឥសី មាតាជាអ្នកឈឺឆ្អាល ជាទីពឹង ជាអ្នកឲ្យរស (ទឹកក្សីរ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ទេវលោក ចង់បានអ្នក។*

**បុព្វេ រសទទី គោត្តី, មាតា បុញ្ញូបសំហិតា;**

**មគ្គោ សគ្គស្ស លោកស្ស, មាតា តំ វរតេ ឥសេ ។**

*មាតាជាអ្នកឲ្យរសជាមុន ជាអ្នកគ្រប់គ្រង ដែលយើងចូលទៅអាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ទេវលោក ម្នាលឥសី មាតាចង់បានអ្នក។*

*ព្រះមហាសត្វពោលគុណម្តាយ ដោយគាថាទាំងឡាយ ២ យ៉ាងនេះហើយ កាលដែលមាតានោះត្រឡប់មកអង្គុយលើអាសនៈវិញ ក៏ពោលថា នៃនន្ទប្អូនបាននូវមាតា ជាអ្នកធ្វើនូវកម្មដែលគេកម្រនឹងធ្វើបាន មាតាចិញ្ចឹមបីបាច់យើងទាំងពីរឲ្យធំចម្រើនបានយ៉ាងលំបាកណាស់ ឥឡូវនេះ ប្អូនចូរកុំប្រមាទ ថែទាំគាត់ចុះ កុំឲ្យលោកពិសាផលាផលនៅខ្ចីដែលមិនទាន់ទុំល្អ មានរសមិនផ្អែមឆ្ងាញ់ទៀតឡើយ ហើយកាល*

*នឹងប្រកាសនូវអំពើដែលមាតាធ្វើដោយសេចក្តីលំបាក ក្នុងកណ្តាលបរិស័ទនោះឯង ទើបពោលថា ៖*

**អាកង្ខមានា បុត្តផលំ, ទេវតាយ នមស្សតិ;**
**នក្ខត្តានិ ច បុច្ឆតិ, ឧតុសំវច្ឆរានិ ច ។**

*មាតាកាលប្រាថ្នាចង់បានផ្លែគឺកូន រមែង នមស្ការទេវតា សួរនក្ខត្តឫក្សទាំងឡាយផង សួររដូវនិង ឆ្នាំទាំងឡាយផង។*

តស្សា ឧតុម្ហិ ន្ហាតាយ, ហោតិ គព្ភស្ស វោក្កមោ;
តេន ទោហឡិនី ហោតិ, សុហទា តេន វុច្ចតិ ។

*កាលមាតានោះ មានរដូវលាងស្អាតហើយ សត្វ ក៏ចុះមកកាន់គភ៌ស៊ប់ មាតាជាស្ត្រីមានសេចក្តីចាញ់ផ្ទៃ ដោយហេតុនេះ ព្រោះហេតុនោះ បានជាបណ្ឌិតហៅ ថា* **សុហទា** *(មានដួងហឫទ័យល្អ)។*

សំវច្ឆរំ វា ឩនំ វា, បរិហរិត្វា វិជាយតិ;
តេន សា ជនយន្តីតិ, ជនេត្តិ តេន វុច្ចតិ ។

មាតារក្សា (ផ្ទៃ) អស់មួយឆ្នាំ ឬថយពីមួយឆ្នាំ ហើយប្រសូតបុត្រមក ព្រោះហេតុនោះ បានជាបណ្ឌិតហៅមាតានោះថា ជនយន្តី ផង ជនេត្តី ផង (អ្នកបង្កើតកូន)។

ថនខីរេន គីតេន, អង្គចាវុរណេន ច;
រោទន្តំ បុត្តំ តោសេតិ, តោសេន្តី តេន វុច្ចតិ ។

មាតាញុំាងកូន ដែលកំពុងយំឲ្យត្រេកអរ ដោយទឹកក្សីរផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា តោសេន្តី (អ្នកញុំាងកូនឲ្យត្រេកអរ)។

តតោ វាតាតបេ ឃោរេ, មមំ កត្វា ឧទិក្ខតិ;

**ធារេតិ អប្បជានន្តំ, ចោសេន្តី តេន វុច្ចតិ ។**

*តពីនោះមក មាតាធ្វើនូវសេចក្តីស្រឡាញ់រាប់អាន ហើយក្រឡេកមើលទារក ដែលនៅពុំទាន់ដឹងក្តី ក្នុងទីមានខ្យល់និងកម្តៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះបានជាបណ្ឌិតហៅថា* **ចោសេន្តី** *(អ្នកចិញ្ចឹមកូន)។*

**យញ្ច មាតុធនំ ហោតិ, យញ្ច ហោតិ បិតុទ្ធនំ;**
**ឧភយម្បេតស្ស គោបេតិ, អបិ បុត្តស្ស នោ សិយា ។**

*ទ្រព្យណាខាងមាតាផង ទ្រព្យខាងបិតាផង មាតាក៏គ្រប់គ្រងទ្រព្យទាំងពីរចំណែកដើម្បីកូននោះ (ដោយបំណងថា ទ្រព្យនេះ) ត្រូវមានដល់ កូនរបស់យើង។*

**ឯវំ បុត្ត អទុំ បុត្ត, ឥតិ មាតា វិហញ្ញតិ;**
**បមត្តំ បរទារេសុ, និសីថេ បត្តយោព្ពនេ;**

សាយំ បុត្តំ អធាយន្តំ, ឥតិ មាតា វិហញ្ញតិ ។

មាតារមែងលំបាកដោយការបង្ហាត់បង្រៀនកូន ដូច្នេះថា ម្នាលកូន (ឯងចូរកុំប្រមាទក្នុងរាជត្រកូលជាដើម) យ៉ាងនេះ ម្នាលកូន (ឯងចូរធ្វើការ) ឯណោះ

កាលបើកូនមានវ័យចម្រើនឡើងហើយ មាតា (បានដឹង) កូននោះប្រមាទក្នុងប្រពន្ធរបស់ អ្នកដទៃក្នុងពេលអធ្រាត្រ ហើយមិនមកក្នុងវេលាល្ងាច ក៏រមែងលំបាកចិត្តដូច្នេះ។

ឯវំ កិច្ឆា ភតោ ពោសោ, មាតុ អបរិចារកោ;
មាតរិ មិច្ឆា ចរិត្វាន, និរយំ សោបបជ្ជតិ ។

សត្វដែលមាតាចិញ្ចឹមដោយក្រដាបក្រដួសយ៉ាងនេះ ហើយមិនបម្រើមាតា ប្រព្រឹត្តខុសក្នុងមាតានោះ តែងទៅកើតក្នុងនរក។

ឃរំ កិច្ចា កតោ ចោសោ, បិតុ អបរិចារកោ;
បិតរិ មិច្ឆា ចរិត្វាន, និរយំ សោបបជ្ជតិ ។

សត្វដែលបិតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើបិតា ប្រព្រឹត្តខុសក្នុងបិតានោះ តែងទៅកើតក្នុងនរក។

ជជាបិ ជនកាមានំ, ឆស្សតិ ឥតិ មេ សុតំ;
មាតរំ អបរិចរិត្វាន, កិច្ចំ វា សោ និគច្ឆតិ ។

យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញឬកូននោះរមែងក្រីក្រលំបាកព្រោះមិនបម្រើមាតា។

ជជាបិ ជនកាមានំ, ឆស្សតិ ឥតិ មេ សុតំ;
បិតរំ អបរិចរិត្វាន, កិច្ចំ វា សោ និគច្ឆតិ ។

យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នក ចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះ រមែងក្រីក្រលំបាកព្រោះមិនបម្រើបិតា។

អានន្ទោ ច បមោទោ ច, សទា ហសិតកីឡិតំ;
មាតរំ បរិចរិត្វាន, លព្ភមេតំ វិជានតោ ។

បណ្ឌិតបម្រើមាតា គប្បីបាននូវសុខនុ៎ះ គឺ សេចក្តីត្រេកអររីករាយ ការសើចលេងសព្វៗកាល។

អានន្ទោ ច បមោទោ ច, សទា ហសិតកីឡិតំ;
បិតរំ បរិចរិត្វាន, លព្ភមេតំ វិជានតោ ។

បណ្ឌិតបម្រើបិតា គប្បីបាននូវសុខនុ៎ះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វៗ កាល។

ទានញ្ច បេយ្យវជ្ជញ្ច, អត្ថចរិយា ច យា ឥធ;
សមានត្តតា ច ធម្មេសុ, តត្ថ តត្ថ យថារហំ;

ឯតេ ខោ សង្គហា លោកេ, រថស្សាណីវ យាយតោ ។

ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តជាប្រយោជន៍ក្នុងលោកនេះ ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើក្នុងជេដ្ឋាបចាយនធម៌នោះៗ តាមសមគួរ ១ៗ

ឯតេ ច សង្គហា នាស្សុ, ន មាតា បុត្តការណា;
លភេថ មានំ បូជំ វា, បិតា វា បុត្តការណា ។

សង្គហធម៌ទាំងនុ៎ះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាភ្លៅនៃកង់រថដែលវិលទៅ បើសង្គហធម៌នុ៎ះមិនមានទេ មាតាមិនត្រូវបាននូវសេចក្តីរាប់អាននិងការបូជា ព្រោះហេតុនៃកូន ទាំងបិតា ក៏មិនត្រូវបាននូវសេចក្តីរាប់អាននិងការបូជា ព្រោះហេតុនៃកូនៗ

យស្មា ច សង្គហា ឯតេ, សម្មបេក្ខន្តិ បណ្ឌិតា;

តស្មា មហត្តំ បប្បោន្តិ, បាសំសា ច ភវន្តិ តេ ។

*ពួកបណ្ឌិត រមែងឃើញដោយល្អនូវសង្គហធម៌ ទាំងនុ៎ះ ព្រោះហេតុណា បណ្ឌិតទាំងនោះ រមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ ដោយហេតុនោះ។*

ព្រហ្មាតិ មាតាបិតរោ, បុព្ពាចរិយាតិ វុច្ចរេ;
អាហុនេយ្យា ច បុត្តានំ, បជាយ អនុកម្បកា ។

*មាតាបិតាជាអ្នកអនុគ្រោះ ដល់ពួកសត្វ គឺបុត្រ បណ្ឌិតហៅថា ព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យៈផង របស់កូនទាំងឡាយ។*

តស្មា ហិ នេ នមស្សេយ្យ, សក្ករេយ្យ ច បណ្ឌិតោ;
អន្នេន អថោ បានេន, វត្ថេន សយនេន ច;
ឧច្ឆាទនេន ន្ហាបនេន, បាទានំ ធោវនេន ច ។

ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូតនិងការលាងជើង។

តាយ នំ ចារិចរិយាយ, មាតាបិតូសុ បណ្ឌិតា;
ឥធេវ នំ បសំសន្តិ, បេច្ច សគ្គេ បមោទតិ ។

បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបម្រើ ចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌។

ព្រះមហាសត្វបញ្ចប់ធម្មទេសនា ដោយប្រការយ៉ាងនេះ ប្រៀបដូចជាការបង្វិលភ្នំសុនេរុ ដូច្នោះឯង។ ព្រះរាជាទាំងអស់ និងកងទ័ពទាំងឡាយ បានស្តាប់ពាក្យនោះហើយ ក៏មានចិត្តត្រេកអររីករាយ ជ្រះថ្លា។

ពេលនោះ សោណបណ្ឌិតបានញុំាងជន
ទាំងឡាយឲ្យតាំងនៅក្នុងសីលទាំង ៥ ហើយទូន្មានថា
អ្នកទាំងឡាយ ចូរកុំប្រមាទក្នុងការឲ្យទានជាដើម
ហើយបញ្ជូនពួកគេឲ្យត្រឡប់វិញ។ ព្រះរាជាទាំងអស់
សោយរាជ្យប្រកបដោយធម៌ កាលសោយទិវង្គត ក៏
បានទៅកើតក្នុងទេវលោក។ ចំណែកសោណបណ្ឌិត
និងនន្ទបណ្ឌិត បម្រើមាតាបិតាដរាបដល់អស់អាយុ
កាលអស់ជីវិតហើយ ក៏បានទៅកាន់ព្រហ្មលោក។

## ជាតកាសោធ

ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមក
ហើយ ទ្រង់ប្រកាសសច្ចធម៌ និងប្រជុំជាតក ក្នុងកាល
ចប់សច្ចធម៌ មាតុបោសកភិក្ខុ (ភិក្ខុចិញ្ចឹមមាតា) បាន
តាំងនៅក្នុងសោតាបត្តិផល ។

- តទា មាតាបិតរោ មាហារាជកុលាធិ

អហោសុំ មាតាបិតា ក្នុងកាលណោះ បានមក

ជាមហារាជត្រកូល (គឺព្រះបាទសុទ្ធោទនៈ និង

ព្រះនាងសិរិមហាមាយា) ។

- ឆន្នបណ្ឌិតោ អានន្ទោ នន្ទបណ្ឌិត បានមក

ជាអានន្ទ ។

- មនោជរាជា សារិបុត្តោ ព្រះបាទមនោជៈ

បានមកជាសារីបុត្រ ។

- ឯកសតរាជានោ អសីតិមហាថេរា ចេវ

អញ្ញតរថេរា ច ស្ដេច ១០១ អង្គ បានមកជា

អសីតិមហាថេរៈ និងជាព្រះថេរៈទាំងឡាយ

ដទៃទៀត ។

- ចតុវីសតិ អក្ខោភណិយោ ពុទ្ធបរិសា

កងទ័ព ២៤ អក្ខោភិនី បានមកជាពុទ្ធបរិស័ទ ។

- សោណបណ្ឌិតោ បន អហមេវ អហោសិំ

បំណែកសោណបណ្ឌិតបានមកជាអង្គអញ

តថាគតនេះឯង ។

សោណនន្ទជាតក ចប់ ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក សត្តតិ-

និបាត ទុតិយជាតក (សោណនន្ទជាតក)

បិដកលេខ ៦១ ទំព័រ៨១-៩៦)

ថ្ងៃព្រហស្បតិ៍ ១២ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ

២៥៦៣, ចុល្លសករាជ ១៣៨១, មហាសករាជ ១៩៤១

ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ គ.ស. ២០២០




**មាតាមានឈ្មោះថា**

សុហជា អ្នកមានដួងហ្ឫទ័យល្អ

ជនយន្តី ឬ ជនេត្តី អ្នកបង្កើតកូន

តោសេន្តី អ្នកញុំាងកូនឲ្យត្រេកអរ

ចោសេន្តី អ្នកចិញ្ចឹមកូន




# មាតាមានឈ្មោះថា

សុហាទា អ្នកមានដួងហឫទ័យល្អ

ជនយន្ដី ឬ ជនេត្តី អ្នកបង្កើតកូន

តោសេន្ដី អ្នកញុំាងកូនឲ្យត្រេកអរ

ថោសេន្ដី អ្នកចិញ្ចឹមកូន